សេចក្តីណែនាំ និង ការពិន័យ
របាយការណ៍អំពីភាពទទួលសិទ្ធិ/ឋានៈ

សម្រាប់ជំនួយជាសាច់ប្រាក់, ប័ណ្ណអាហារូបត្ថម្ភ

ត្រូវការជំនួយ? សូមទូរស័ព្ទទៅបុគ្គលិករបស់លោកអ្នក ។

- ប្រសិនបើលោកអ្នកមិនផ្ញើរបាយការណ៍ពេញលេញ រួមបញ្ចូលទាំង ប៉ុន្តែមិនកំណត់ចំពោះការឆ្លើយសំណួរទាំងអស់នៅលើ QR 7/SAWS QR 7 និង ការភ្ជាប់ភស្តុតាង នៅពេលយើងស្នើសុំវា ផលប្រយោជន៍របស់លោកអ្នកអាចត្រូវបានពន្យារពេល, ផ្អាស់ប្តូរ ឬ បញ្ឈប់ ។ **សូមភ្ជាប់សន្លឹកក្រដាសដាច់ដោយឡែកប្រសិនបើត្រូវការ ។**
- ព័ត៌មានដែលលោកអ្នករាយការណ៍អាចធ្វើឱ្យផលប្រយោជន៍របស់លោកអ្នកកើនឡើង, ថយចុះ ឬ បញ្ឈប់ ។
- សូមផ្ញើរបាយការណ៍ដែលបានបំពេញរួចរបស់លោកអ្នកឱ្យបានទាន់ថ្ងៃទី ៥ នៃខែបន្ទាប់ពីខែរាយការណ៍ ។

ឧទាហរណ៍

ចំណូល

- ប្រៃវត្សរ៍ប្រចាំសប្តាហ៍
- ប្រាក់វិស្សមកាល
- ការឧបត្ថម្ភកូន/ប្រពន្ធ
- ការធានារ៉ាប់រង ឬ ការតាំងទីលំនៅដោយស្របច្បាប់
- ចំណូលសម្រាប់ការជួលផ្ទះ និង ជំនួយសម្រាប់ការជួលផ្ទះ
- ផលប្រយោជន៍រដ្ឋាភិបាលណាមួយ
- សំណងពិការភាពរបស់រដ្ឋ
- ការរកស៊ីផ្ទាល់ខ្លួន
- ប្រាក់ចឹកតែ
- ការប្រាក់ ឬ ភាគលាភ
- ប្រយោជន៍កូដកម្ម
- ប្រាក់ពន្ធដែលទទួលបានមកវិញ
- និវត្តភាព
- សុវត្ថិភាពសង្គម
- ចំណូលសុវត្ថិភាពបន្ថែម/ ការចំណាយបន្ថែមរបស់រដ្ឋ (SSI/SSP)
- ប្រាក់ប្រៃវត្សរ៍
- ចំណូល ជាប្រភេទ ដូចជា ការស្នាក់នៅដោយទទួលចំណូល, ការស្នាក់នៅ/ទឹកភ្លើង/សម្លៀកបំពាក់/អាហារដោយឥតបង់ប្រាក់
- ការឈ្នះល្បែង/ឆ្នោត
- សាច់ប្រាក់, អំណោយ, កម្ចី, អាហារូបករណ៍
- ពិការភាព ឬ ការចូលនិវត្តន៍ ជាឯកជន ឬ រដ្ឋាភិបាលផ្សេងទៀត
- សំណេងបុគ្គលិក
- ទាហានជើងចាស់ ឬ ការចូលនិវត្តន៍ របស់អ្នកធ្វើផ្លូវរថភ្លើង

ទ្រព្យសម្បត្តិ

- យានយន្តម៉ូតូ
- សមតុល្យ EBT
- ផ្ទះ
- ចរន្ត
- មូលប័ត្រសន្សំ
- ដី
- សន្សំ
- កិច្ចសន្យាធានារ៉ាប់រងជីវិត
- ភារៈគ្រប់គ្រង

ថ្លៃស្នាក់នៅ

- ជួល
- ទឹកភ្លើង
- បញ្ចាំ
- ការធានារ៉ាប់រងរបស់ម្ចាស់ផ្ទះ
- ពន្ធលើទ្រព្យសម្បត្តិ
- ថ្លៃប្រមូលសម្រាម/សំណល់

ការចំណាយ

- ការចំណាយវេជ្ជសាស្ត្រ
- ការធានារ៉ាប់រងសុខភាព
- ការថែទាំក្មេង/មនុស្សក្រោមបន្ទុក
- ថ្លៃ និង គ្រឿងបរិក្ខាសិក្សានៅមហាវិទ្យាល័យ
- ថ្លៃសាលាដែលចាំបាច់
- ការឧបត្ថម្ភកូន/ប្រពន្ធ
- ការធ្វើដំណើរ
- បន្ទប់ និង អាហារ
- ថ្លៃស្នាក់នៅ

ការពិន័យ

ការពិន័យសម្រាប់ការក្លែងបន្លំជំនួយជាសាច់ប្រាក់ : ប្រសិនបើមានចេតនា លោកអ្នកមិនធ្វើតាមបទបញ្ជតិជំនួយជាសាច់ប្រាក់ ជំនួយជាសាច់ប្រាក់របស់លោកអ្នកអាចត្រូវបានបន្តយសម្រាប់មួយអំឡុងពេល ហើយលោកអ្នកអាចនឹងត្រូវបានពិន័យដល់ទៅ ១0.000 ដុល្លា និង/ឬ បញ្ជូនទៅមន្ទីឃុំឃាំង ឬ ពន្ធធនាគារ សម្រាប់រយៈពេលដល់ទៅ ៣ ឆ្នាំ ។

ជំនួយជាសាច់ប្រាក់របស់លោកអ្នកអាចត្រូវបានបញ្ឈប់ :

- សម្រាប់ការមិនរាយការណ៍ព័ត៌មានទាំងអស់ ឬ សម្រាប់ការផ្តល់ព័ត៌មានមិនពិត : ៦ ខែ សម្រាប់ការប្រព្រឹត្តិល្មើសលើកទី១, ១២ ខែ សម្រាប់ការប្រព្រឹត្តិល្មើសលើកទី២ ឬ ជារៀងរហូត សម្រាប់ការប្រព្រឹត្តិល្មើសលើកទី៣ ។
- សម្រាប់ការដាក់ពាក្យសុំមួយ ឬ ច្រើន ដើម្បីទទួលជំនួយលើសពីមួយករណី ក្នុងរយៈពេលតែមួយ : ២ ឆ្នាំសម្រាប់ការកាត់ទោសលើកទី១, ៤ ឆ្នាំសម្រាប់លើកទី២ និង ជារៀងរហូត សម្រាប់លើកទី៣ ។
- សម្រាប់ការកាត់ទោសពីការក្លែងបន្លំដែលជាបទឧក្រិដ្ឋដើម្បីទទួលជំនួយ : ២ ឆ្នាំ សម្រាប់ការលួចទូរទំចំនួនក្រោម ២000 ដុល្លា, ៥ ឆ្នាំសម្រាប់ចំនួន ២000 ដុល្លា ដល់ ៤៩៩៩.៩៩ ដុល្លា និង ជារៀងរហូតសម្រាប់ចំនួន ៥000 ដុល្លា ឬ ច្រើនជាងនេះ ។
- ជារៀងរហូត : សម្រាប់ការផ្តល់ឱ្យស្រុកនូវភស្តុតាងមិនពិតពីការស្នាក់នៅដើម្បីទទួលជំនួយនៅក្នុងស្រុក ឬ រដ្ឋ ពីរ ឬ ច្រើន នៅពេលតែមួយ, ផ្តល់ឱ្យស្រុកនូវព័ត៌មានមិនពិត សម្រាប់ក្មេងដែលមិនទទួលសិទ្ធិ ឬ ក្មេងដែលមិនមាន, ការទទួលបានលើសពី ១0.000 ដុល្លា ជាផលប្រយោជន៍ជាសាច់ប្រាក់ តាមរយៈការបន្លំ, ការទទួលការកាត់ទោសលើកទី៣ សម្រាប់ការក្លែងបន្លំនៅក្នុងតុលាការឆ្បាប់ ឬ សវនាការរដ្ឋបាល ។

ការពិន័យសម្រាប់ការក្លែងបន្លំប័ណ្ណអាហារូបត្ថម្ភ : ប្រសិនបើមានចេតនា លោកអ្នកមិនធ្វើតាមបទបញ្ជតិប័ណ្ណអាហារូបត្ថម្ភ ប័ណ្ណអាហារូបត្ថម្ភរបស់លោកអ្នកអាចត្រូវបានបញ្ឈប់សម្រាប់រយៈពេល ១២ ខែ សម្រាប់ការប្រព្រឹត្តិល្មើសលើកទី១, ២៤ ខែ សម្រាប់លើកទី ២ និង ជារៀងរហូតសម្រាប់លើកទី ៣ ។ លោកអ្នកអាចត្រូវបានពិន័យដល់ទៅ ២៥0.000 ដុល្លា និង/ឬ បញ្ជូនទៅមន្ទីឃុំឃាំង/ ពន្ធធនាគារ រយៈពេល ២0 ឆ្នាំ ។

- **ប្រសិនបើលោកអ្នកត្រូវបានរកឃើញថាមានកំហុសនៅក្នុងតុលាការឆ្បាប់ ឬ សវនាការរដ្ឋបាលណាមួយ ពីព្រោះ :**
- លោកអ្នកបានជួញដូរ ឬ បានលក់ប័ណ្ណអាហារូបត្ថម្ភដើម្បីដូរយកកាំភ្លើង, អាវុធយុទ្ធភ័ណ្ឌ, ឬ គ្រឿងផ្ទុះ ប័ណ្ណអាហារូបត្ថម្ភរបស់លោកអ្នកអាចត្រូវបានបញ្ឈប់ជារៀងរហូតសម្រាប់ការប្រព្រឹត្តិល្មើសលើកទី១ ។
- លោកអ្នកបានជួញដូរ ឬ បានលក់ប័ណ្ណអាហារូបត្ថម្ភដើម្បីដូរយកសារធាតុហាមឃាត់ ប័ណ្ណអាហារូបត្ថម្ភរបស់លោកអ្នកអាចត្រូវបានបញ្ឈប់ ក្នុងរយៈពេល ២៤ ខែ សម្រាប់ការប្រព្រឹត្តិល្មើសលើកទី១ និង ជារៀងរហូត សម្រាប់លើកទី ២ ។
- លោកអ្នកបានជួញដូរ ឬ បានលក់ប័ណ្ណអាហារូបត្ថម្ភដែលមានតម្លៃ ៥00 ដុល្លា ឬ ច្រើនជាងនេះ ប័ណ្ណអាហារូបត្ថម្ភរបស់លោកអ្នកអាចត្រូវបានបញ្ឈប់ជារៀងរហូត ។
- លោកអ្នកបានផ្តល់ឱ្យស្រុកនូវព័ត៌មានអត្តសញ្ញាណ ឬ ការស្នាក់នៅមិនពិត ដូច្នេះ លោកអ្នកអាចទទួលប័ណ្ណអាហារូបត្ថម្ភច្រើនជាងមួយករណីនៅក្នុងពេលតែមួយ ប័ណ្ណអាហារូបត្ថម្ភរបស់លោកអ្នក អាចត្រូវបានបញ្ឈប់ ក្នុងរយៈពេល ១0 ឆ្នាំ ។